ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚៚៚

តុលាការកំពូល

៚៚

សភាផ្នែកព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ២៧

ចុះថ្ងៃទី០៩ខែមិថុនាឆ្នាំ១៩៩៨

សាលដីកា

លេខ : ០៥

ចុះថ្ងៃទី០៣ខែមិនាឆ្នាំ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ១៩៩៩

ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះ ដូចតទៅ :

១ - ឯកឧត្តម ឌិត មុន្ទី ប្រធាន

២ - លោក ឈឹម ស៊ីផល ចៅក្រម

៣ - លោក ឡោម សិរីវឌ្ឍ ចៅក្រម

៤ - លោក ប្រាក់ គឹមសាន ចៅក្រមរាយការណ៍

៥ - លោក យស់ ឈូខឿន ចៅក្រម

លោក ទេព ចាន់ថា ក្រឡាបញ្ជី

តំណាងមហាអយ្យការ លោក ដួន ស៊ុនទៀង ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ ២៥៤ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ ២៧ ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ១៩៩៨ របស់តុលាការកំពូល

ពីបទ : ពង្រត់មនុស្សយកទៅលក់ ប្រព្រឹត្តនៅភូមិ ទ្រាងបទ័ន្ធ ឃុំស្វាយទៀង ស្រុក-ខេត្ត ស្វាយរៀង កាលពីថ្ងៃទី ២៥ ខែឧសភា ឆ្នាំ១៩៩៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និង អំពើធ្វើអាជីវកម្មលើមនុស្ស ។

- ជនជាប់ចោទឈ្មោះ ស្រី ពៅ ហៅ ភាព "ចុងបណ្តឹងសាទុក្ខ" ភេទស្រី អាយុ ២៩ ឆ្នាំ ជាតិខ្មែរ មុខរបរ មេផ្ទះ ទីលំនៅមុនពេលចាប់ខ្លួន នៅភូមិម្លាង ឃុំតាដែង ស្រុកបាធាយ ខេត្តកំពង់ចាម ។ ឪពុកឈ្មោះ ទុំ សំអុល "ស" ម្តាយឈ្មោះ ជ័យ ឡេង "ស" ប្តីឈ្មោះ អ៊ី វ៉ាន្នី មានកូន ២ នាក់ ។ ទោសពីមុនគ្មាន នៅក្នុងឃុំ ចាប់ខ្លួនថ្ងៃទី ០៤-៨-៩៦ ឃុំខ្លួនថ្ងៃទី ០៦-៨-៩៦ "អវត្តមាន" មេធាវី គ្មាន ។

- ជនជាប់ចោទឈ្មោះ អ៊ុំ សុផាត ហៅ ណន "ម្ចាស់បណ្តឹងសាទុក្ខ" ភេទស្រី អាយុ ៤៣ ឆ្នាំ ជាតិខ្មែរ មុខរបរ កាត់ដេរ ទីលំនៅសព្វថ្ងៃនៅភូមិចុងព្រែក ឃុំស្វាយទៀង ស្រុក-ខេត្តស្វាយរៀង ឪពុកឈ្មោះ អ៊ុំ យ៉ន "រ" ម្តាយឈ្មោះ គឹម ពៅ "រ" ប្តីឈ្មោះ គង់ ទេង មានកូន ៥ នាក់ ទោសពីមុន គ្មាន នៅក្រៅឃុំ មេធាវីលោក លូ អ៊ុន ។

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះអ្នកស្រី ប៉ែន អៃ "ចុងបណ្ដឹងសាទុក្ខ" ម្ដាយរបស់ជនរងគ្រោះ ឈ្មោះកុមារី ប៉ែន វន្នី ហៅ មុំ អាយុ ៤៣ ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើពេទ្យ ទីលំនៅសព្វថ្ងៃនៅភូមិរោងបន្លែ ឃុំស្វាយរៀង ស្រុក-ខេត្ត ស្វាយរៀង ។ មេធាវី គ្មាន "អវត្តមាន"

តាមបណ្ដឹងសាទុក្ខលេខ ០៤ ចុះថ្ងៃទី ១៩ខែមករាឆ្នាំ១៩៩៨ របស់ជនជាប់ចោទឈ្មោះ អ៊ុំ សុផាត ដែលប្ដឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ២៥៤ ចុះថ្ងៃទី ២៦-១២-៩៧ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសំរេចទាំងមូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី ០៦-៦-៩៦ របស់អ្នកស្រី ប៉ែន អៃ និង របាយការណ៍លេខ ០៩៧ ចុះថ្ងៃទី ០៦-៨-៩៦ របស់ស្នងការនគរបាលខេត្តស្វាយរៀង ថា : កាលពីថ្ងៃទី ២៤-៥-៩៦ វេលាម៉ោង ៥ ល្ងាច ឈ្មោះ ស្រី ពៅ ហៅ ភាព ជាប្អូនថ្លៃរបស់ឈ្មោះ អ៊ុំ សុផាត បានមកអង្គុយលេងនៅផ្ទះឈ្មោះ ប៉ែន អៃ ហើយបានទិញនំអោយឈ្មោះ ប៉ែន វន្នី ហៅ មុំ ជាកូនស្រីរបស់ឈ្មោះ ប៉ែន អៃ ស៊ី និង រកចៃអោយ ហើយបានបបួលកូនស្រីនោះទៅលេងស្រុករបស់ខ្លួន ។ នៅថ្ងៃទី ២៥-៥-៩៦ វេលាម៉ោង ៧ ព្រឹក ឈ្មោះ ប៉ែន វន្នី ត្រូវបាត់ខ្លួន ឯឈ្មោះ ស្រី ពៅ ក៏បាត់ខ្លួនដែរ ។ លុះដល់ថ្ងៃទី០២-៦-៩៦ ឈ្មោះ ស្រី ពៅ បានត្រឡប់មកផ្ទះឈ្មោះ អ៊ុំ សុផាត វិញ តែឈ្មោះ ប៉ែន អៃ ពុំបានសួរនាំអ្វីឡើយ ។ នៅថ្ងៃទី ០៦-៦-៩៦ ឈ្មោះ ស្រី ពៅ បំរុងចេញដំណើរទៅស្រុកវិញ ឈ្មោះ ប៉ែន អៃ បានប្ដឹងសមត្ថកិច្ចស្រុក និង ខេត្ត ។ ក៏បានឃាត់ខ្លួន ស្រី ពៅ ភ្លាម តែដោយស៊ើបសួរគ្មានមូលដ្ឋានចោទ ទើបអោយស្រី ពៅ ត្រឡប់ទៅផ្ទះវិញ ។ នៅថ្ងៃទី ២៥-៧-៩៦ ទើបដឹងដំណឹងថា ឈ្មោះ ប៉ែន វន្នី នៅតំបន់ ៥ ខេត្តបន្ទាយ-មានជ័យ ។ ពេលត្រឡប់មកផ្ទះវិញឈ្មោះ ប៉ែន វន្នី បញ្ជាក់ច្បាស់ថា ស្រី ពៅ នាំខ្លួនយកទៅលក់ដល់ប្រទេសថៃ ។ នៅថ្ងៃទី ០៤-៨-៩៦ វេលាម៉ោង ៣ ល្ងាច ឈ្មោះ ស្រី ពៅ បានចូលមកដល់មូលដ្ឋានវិញ សមត្ថកិច្ចស្រុកស្វាយរៀងបានឃាត់ខ្លួន ហើយឈ្មោះនេះបានសារភាពថា ខ្លួនពិតជាបាននាំកុមារី ប៉ែន វន្នី ហៅ មុំ ទៅលក់ដល់ប្រទេសថៃមែន ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការខេត្តស្វាយរៀង ថា : មានពិរុទ្ធគ្រប់គ្រាន់លើឈ្មោះនារី ស្រី ពៅ ហៅ ភាព និង ឈ្មោះនារី អ៊ុំ សុផាត ហៅ ណន ពីបទ : ពង្រត់មនុស្សយកទៅលក់ ប្រព្រឹត្តនៅភូមិ រោងបន្លែ ឃុំស្វាយរៀង ស្រុក-ខេត្ត ស្វាយរៀង កាលពីថ្ងៃទី២៥-៥-៩៦ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្ដន្ទាទោសតាមមាត្រា ០៣ នៃច្បាប់បង្ក្រាបអំពើពង្រត់ និង លក់ដូរមនុស្ស ។ ហើយសំរេចដីកាសន្និដ្ឋានស្ថាពរលេខ ២៩២ អ.ច ចុះថ្ងៃទី ១៩-១២-៩៦ របស់ព្រះរាជអាជ្ញាអមតុលាការខេត្តស្វាយរៀង ទុកជាបានការពេញទាំងមូល និង ស្នើសុំតុលាការផ្ដន្ទាទោសជនល្មើស តាមច្បាប់ជាធរមាន ។ រីឯសំណង រដ្ឋប្បវេណី អាស្រ័យលើតុលាការពិនិត្យ និង សំរេចតាមលទ្ធភាពជាក់ស្ដែង ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ០៨ ចុះថ្ងៃទី ០៤-០២-៩៧ របស់តុលាការខេត្តស្វាយរៀង ដែលបានសំរេចសេចក្ដីដូចតទៅ :

១ - ផ្តន្ទាទោសឈ្មោះនារី ស្រី ពៅ "ភាព" ដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ គិតពីថ្ងៃឃុំខ្លួន

- ផ្តន្ទាទោសឈ្មោះនារី អ៊ុំ សុផាត "ណាន" ដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន ដាក់ពន្ធនាគារ ពីបទ : រួបរួមគ្នាពង្រត់មនុស្សយកទៅលក់ ប្រព្រឹត្តនៅភូមិ ទោងបន្ទី ឃុំស្វាយ-ទៀង ស្រុក-ខេត្ត ស្វាយទៀង កាលពីថ្ងៃទី ២៥-៨-៩៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ០៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និង លក់ដូរមនុស្ស និង អំពើធ្វើអាជីវកម្មលើមនុស្ស ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជ.ស-រកម ០២.៩៦ ០១ ចុះថ្ងៃទី ២៩ខែកុម្ភៈឆ្នាំ១៩៩៦ ។

២ - អោយឈ្មោះនារី ស្រី ពៅ និង ឈ្មោះនារី អ៊ុំ សុផាត រួបរួមគ្នាសងសំណងជំងឺចិត្ត និង ការខាតបង់ផ្សេង ៗ ក្នុងការតាមរកកូន ទៅឈ្មោះនារី ប៉ែន អែ ដើមបណ្តឹងរដ្ឋប្បវេណីជាប្រាក់ចំនួន ២.០០០.០០០រៀល ។ សំណើលើសពីនេះត្រូវលើកចោល ។

បើពុំមានប្រាក់សងគ្រប់ចំនួនទេ ត្រូវអនុវត្តមាត្រា ៧ និង មាត្រា ៨ នៃច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ គឺ ១ថ្ងៃ x ១០០,០០០ / ៥០០ + ១ថ្ងៃ x ១.៩០០.០០០ / ១០០០ = ២០០០ថ្ងៃ

៣ - សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី ។ បើកផ្លូវឧទ្ធរណ៍រយះ ២ ខែ គិតពីថ្ងៃនេះតទៅ ។

- បាន ឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៤-០២-៩៧ របស់ឈ្មោះ អ៊ុំ សុផាត ប្តឹងមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ ០៨ ចុះថ្ងៃទី ០៤-០២-៩៧ របស់តុលាការខេត្តស្វាយទៀងត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

- បាន ឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ថា : ឈ្មោះស្រី ពៅ បាន ឆ្លើយសារភាពរួចហើយ ពេលតុលាការកាត់សេចក្តីហើយឈ្មោះនេះ ពុំបានប្តឹងតវ៉ាទៀតទេ ។ ឯឈ្មោះ អ៊ុំ សុផាត ឆ្លើយពុំពិតទេ ព្រោះឈ្មោះ ស្រី ពៅ ឆ្លើយនៅមុខព្រះរាជអាជ្ញា និងឆ្លើយនៅមុខចៅក្រមស៊ើបអង្កេត ឈ្មោះ ស្រី ពៅ នៅរក្សាចំលើយរបស់ខ្លួនដដែល ។ សូមកែប្រែបទល្មើស ពីបទ : រួមគ្នាពង្រត់មនុស្សយកទៅលក់ ទៅជាបទល្មើសសមគំនិតពង្រត់មនុស្សយកទៅលក់ ។

- បាន ឃើញសាលដីកាព្រហ្មទណ្ឌលេខ ២៥៤ ចុះថ្ងៃទី ២៦-១២-៩៧ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១ - ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ អ៊ុំ សុផាត ចុះថ្ងៃទី ០៤-០២-៩៧ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២ - តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៨ ចុះថ្ងៃទី ០២-០២-៩៧ របស់តុលាការខេត្តស្វាយទៀង ទុកជាបានការ វៀរលែងតែ :

- ចំណុចទី១ វាក្យខណ្ឌ២ ត្រង់កំណត់ដាក់ពន្ធនាគារចំនួន ១៥ ឆ្នាំ កែប្រែមកជា ១០ឆ្នាំ និង វាក្យខណ្ឌ៣ ត្រង់ពាក្យថា " ដាក់ពន្ធនាគារពីបទរួបរួមគ្នាពង្រត់មនុស្សយកទៅលក់ " ត្រូវលុបចោល ហើយដាក់ថា " ពីបទពង្រត់មនុស្សយកទៅលក់ និង បទសមគំនិត ពង្រត់មនុស្សយកទៅលក់ " ជំនួសវិញ ។

- និងចំណុចទី២ វាក្យខណ្ឌ២ ត្រូវលុបចោលទាំងអស់ ហើយដាក់ថា " ករណីឈ្មោះខាងលើគ្មានប្រាក់សង បង្គាប់អោយដាក់គុកបង្ខំរូបកាយ ដើម្បីទារធនទណ្ឌ តាមបញ្ញត្តិមាត្រា ៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំរូបកាយ ក្នុងរឿងព្រហ្មទណ្ឌ ។

យោងតាមបញ្ញត្តិមាត្រា ៦៨ ,៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ ០៤ ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ១៩៩៩ របស់ឈ្មោះ អ៊ុំ សុផាត ប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ ២៥៤ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណាការពារចុះថ្ងៃទី ១១.០៧.៩៨ របស់ម្ចាស់បណ្តឹងសាទុក្ខឈ្មោះ អ៊ុំ សុផាត ។

- បានឃើញសារណាឆ្លើយតបចុះថ្ងៃទី ១០.១១.៩៨ របស់ចុងបណ្តឹងសាទុក្ខឈ្មោះចាន់ សារឿន

- បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា : មានពិរុទ្ធគ្រប់គ្រាន់លើឈ្មោះ អ៊ុំ សុផាត ពីបទ សមគំនិតក្នុងការពង្រត់កុមារី ប៉ែន រិន្ទី យកទៅលក់ប្រាកដមែន បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ០៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និង លក់ដូរមនុស្ស និង អំពើធ្វើអាជីវកម្មលើមនុស្ស ។ មហាអយ្យការយល់ឃើញថា : សាលដីកាលេខ ២៥៤ ចុះថ្ងៃទី ២៦.១២.៩៧ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ សូមក្រុមប្រឹក្សាជំនុំជំរះពិនិត្យ និង សំរេច ។

- បានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ អ៊ឹ សុផាត ថា : កាលពីថ្ងៃ ខែ ឆ្នាំ មិនចាំ ប្អូនប្រុសខ្លួនឈ្មោះ អ៊ុំ រិន្ទី ដែលបានបែកពីខ្លួនតាំងពីឆ្នាំ១៩៧៨ បានមកជួបខ្លួន មានទាំងប្រពន្ធឈ្មោះ ស្រី ពៅ និង កូន ២ នាក់មកជាមួយផង បានស្នាក់នៅលេងជាមួយខ្លួនប្រហែលជាង ១០ ថ្ងៃ ។ ឈ្មោះ ស្រី ពៅ ត្រូវជាប្អូនថ្លៃ សុំធ្វើដំណើរទៅស្រុកកំណើតនៅខេត្តកំពង់ធំ ដើម្បីរកលុយបងប្អូន ។ ប្អូនប្រុសខ្លួនឈ្មោះ អ៊ុំ រិន្ទី ក៏ជូនដំណើរមកឡើងឡាននៅបេន ។ ខ្លួនមិនបានជូនដំណើរមកឡើងឡានទេ គឺខ្លួននៅផ្ទះ ។ ខ្លួនក៏ឃើញប្អូនប្រុសឈ្មោះ អ៊ុំ រិន្ទី ត្រឡប់មកផ្ទះវិញ ។ រំលងបាន ៨ ឬ ៩ ថ្ងៃ ក៏ឃើញឈ្មោះ ស្រី ពៅ ត្រឡប់មកវិញ ក៏នាំប្តី នាំកូន និយាយថា : ទៅលិចវិញ ។ ក្រៅពីនេះខ្លួនមិនបានដឹងអ្វីទៀតទេ ។ ខ្លួនសូមអោយតុលាការកំពូល មេត្តាជួយរកយុត្តិធម៌អោយខ្លួន ដោយក្តីអនុគ្រោះផង ។

- បានស្តាប់សារណាឆ្លើយតបរបស់ឈ្មោះ ចាន់ សារឿន ត្រូវជាឪពុកជនរងគ្រោះ កុមារីឈ្មោះ ប៉ែន រិន្ទី ។

- បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ ថា : ពាក់ព័ន្ធនឹងការកាត់ក្តីនៅតុលាការខេត្តស្វាយរៀង តុលាការអង្កេតតែលើកទី ១ ដាក់បន្ទុកអោយកូនក្តីខ្លួន ឈ្មោះអ៊ុំ សុផាត គឺ ពុំបានអង្កេតដោះបន្ទុកឡើយ ។ ម្យ៉ាងទៀត កូនក្តីខ្លួនបានខ្ចីលុយគេអោយប្អូនប្រុសខ្លួនធ្វើដំណើរទៅស្រុកវិញ ពុំបានដឹងរឿងអ្វីឡើយ ។ ចំពោះសាក្សីវិញ តុលាការកោះហៅសួរតែសាក្សីដាក់បន្ទុក

ប៉ុន្តែសាក្សីដោះបន្ទុក តុលាការពុំបានកោះហៅមកសួរទេឡើយ ។ ចំណែកនៅសាលាឧទ្ធរណ៍ ពុំបានតែងតាំង រឺ រកមេធាវីអោយកូនក្តីខ្លួនឈ្មោះ អ៊ុំ សុផាត នេះទៀយ នាំអោយការការពារ រឺ សួរក្នុងពេលសវនាការ មានការខ្វះចន្លោះជាពុំខាន ។ ហើយនៅក្នុងសារណារបស់កូនក្តីខ្លួនដែលបានជូនមកតុលាការកំពូល នៅតែបដិសេធពុំទទួលនឹងព្រឹត្តិការណ៍អ្វីទាក់ទងនឹងការពង្រត់កុមារីរងគ្រោះនេះទៀយ ។ ខ្លួនជាមេធាវីអោយជនជាប់ចោទឈ្មោះ អ៊ុំ សុផាត សូមអោយក្រុមប្រឹក្សាជំនុំជំរះ មេត្តាករុណាធម៌អោយកូនក្តីខ្លួនបានរួចផុតពីការចោទប្រកាន់ទោសនេះ ដោយក្តីអនុគ្រោះផង ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុ លា កា រ កំ ពូ ល

- ឃើញថា ពាក្យបណ្តឹងសាទុក្ខលេខ ០៤ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ៩៩៨ របស់ឈ្មោះអ៊ុំ សុផាត ធ្វើទៀងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ៦៨ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់តុលាការកំពូល ។

- ឃើញថា ការដែលតុលាការខេត្តកណ្តាល និងសាលាឧទ្ធរណ៍សំរេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ អ៊ុំ សុផាត ពីបទរំលោភសេព ក្នុងអំពើពង្រត់ និង លក់ដូរមនុស្ស និង ធ្វើអាជីវកម្មលើមនុស្ស ដោយអាងតែថា មានភស្តុតាងគ្រប់គ្រាន់ហើយនោះ ជាការមិនត្រឹមត្រូវ ពីព្រោះថា សំណុំរឿងទាំងអស់ដែលតុលាការខេត្តកណ្តាល និង សាលាឧទ្ធរណ៍លើករឿងផ្អែកតាមតែចម្លើយរបស់ចាស៊ី និង ជនរងគ្រោះតែប៉ុណ្ណោះ ដែលពុំអាចកំណត់បានថា មានមូលដ្ឋានគ្រប់គ្រាន់បញ្ជាក់ថា ឈ្មោះ អ៊ុំ សុផាត ពិតជាបានចូលរួមក្នុងអំពើពង្រត់កុមារីឈ្មោះ ប៉ែន រ៉ានី ឯករាជ្យក៏ទៀយ ។ តុលាការក៏មិនធ្វើការស៊ើបអង្កេតបន្ថែមទៀត ថាតើឈ្មោះ អ៊ុំសុផាត ពិតជាបានជូនដំណើរឈ្មោះ ស្រី ពៅ ហៅ ភាព ទៅព្រែកថ្លឹងគីឡូម៉ែត្រ និង ពិតជាបានផ្តល់មធ្យោបាយក្នុងការពង្រត់កុមារីឈ្មោះ ប៉ែន រ៉ានី មែនឬទេ ?

- ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសារណាជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- ឃើញថា សាលដីកាឧទ្ធរណ៍លេខ ៤៨៥ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានការខុសឆ្គង ទាំងទំរង់ ទាំងអង្គច្បាប់ ។

ហេ តុ ដូ ច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទ

កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ

១ - ទទួលបណ្ដឹងសាទុក្ខលេខ ០៤ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ១៩៩៨ របស់ឈ្មោះ អ៊ុំ សុផាត ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - ទុកជាមោឃៈ សាលដីកាព្រហ្មទណ្ឌលេខ ២៨៤ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ របស់ សាលាឧទ្ធរណ៍ទាំងមូល ។

៣ - បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ២៧ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ១៩៩៨ របស់តុលាការ កំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤ - សាលដីកានេះ ជំនុំជំរះនៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ១៩៩៩ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ០៣ ខែ មិនា ឆ្នាំ១៩៩៩ ។